ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**អគ្គិសនីកម្ពុជា**

**គណៈកម្មាធិការលទ្ធកម្ម**

លេខ : 798 PEAC.អក

## សេចក្តីជូនដំណឹងលើកទី២

## ស្តីពី

## ការផ្គត់ផ្គង់សំភារៈការពារសុវត្ថិភាពពលកម្មចំនួន០៨មុខ

## ជូននាយកដ្ឋានអាជីវកម្មចែកចាយ

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តា ក្រុមហ៊ុន/សហគ្រាស(គិតទាំងសហគ្រាស ឯកត្តបុគ្គល ) ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា : អគ្គិសនីកម្ពុជានឹងដាក់ឱ្យពិគ្រោះថ្លៃជាសាធារណៈ ដើម្បី ផ្គត់ផ្គង់សំភារៈការពារសុវត្ថិភាពពលកម្មចំនួន០៨មុខជូននាយកដ្ឋានអាជីវកម្មចែកចាយ ។

អគ្គិសនីកម្ពុជាបានរៀបចំឯកសារសំរាប់ក្រុមហ៊ុន /សហគ្រាសបំពេញ ដើម្បីចូលរួមពិគ្រោះថ្លៃ ។ ឯកសារពិគ្រោះថ្លៃមានដាក់លក់នៅអង្គភាពលទ្ធកម្ម ដែលមានអាស័យដ្ឋានៈ ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ ចាប់ពី ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៧ តទៅរៀងរាល់ម៉ោងធ្វើការ ( ទូរស័ព្ទទាក់ទងលេខ : 023 67 66 007 និង Website : ( www.edc.com.kh) ។

ឯកសារពិគ្រោះថ្លៃដែលបានបំពេញរួចត្រូវប្រគល់ជូនអង្គភាពលទ្ធកម្មយ៉ាងយូរបំផុតត្រឹមថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៧ វេលាម៉ោង ១១:០០ នាទី ។

ការបើកសំណើពិគ្រោះថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាស័យដ្ឋានខាងលើវេលាម៉ោង ១៥:៤៥នាទី ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៧ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើពិគ្រោះថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមពិគ្រោះថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារពិគ្រោះថ្លៃ និង សាកសួរពតិមានដែលទាក់ទងនឹងការពិគ្រោះថ្លៃនេះ ។ /.

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី 17 ខែឧសភា ឆ្នាំ ២០១៧

**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

ឆឹង_អ៊ឹង

ចម្លងជូន :

-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

-អង្គភាពប្រឆាំងអំពើពុករលួយ